# ព្រឹត្តិបត្រព័ត៌មាន

## សាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន ពាមជីកង

លេខ០៧ ខែកក្កដា ឆ្នាំ២០២៤

ហ្វេសប៊ុកផេក៖ វិទ្យាល័យ ហ៊ុនសែន ពាមជីកងជំនាន់ថ្មី
លេខទូរសព្ទ៖ 096 7273 921/ 087 609 156
គេហទំព័រ www.pck.ngs.edu.kh
អ៊ីម៉ែល៖ ngspckhighschool@gmail.com

## មាតិកា

- ការចែករំលែកអាជីពជាគ្រូពេទ្យ និងការថែរក្សាសុខភាពចំពោះក្មេងស្រី
- បណ្ណាល័យសតវត្សទី២១ នៃ វិទ្យាល័យ ហ៊ុន សែន ពាមជីកង
- ការរៀបចំធ្វើការីយ៉ូទីប
- ការសម្តែង(Role play)ក្នុងអំណាន”អាពាហ៍ពិពាហ៍របស់ខ្មែរ”
- ការញែក ADN ចេញពីផ្លែឈើទុំ (ផ្លែចេកណាំវ៉ា និង ផ្លែប៉េងប៉ោះ)
- បំណិនជីវិត
- សកម្មភាពប្រឡងឆមាសលើកទី២ ថ្នាក់ទី១២
- ពិធីសំណេះសំណាលជាមួយសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែនពាមជីកង
- សកម្មភាពប្រឡងឆមាសលើកទី២ ថ្នាក់ទី៩
- សកម្មភាពប្រឡងប្រចាំខែកក្កដា ថ្នាក់ទី៧, ៨, ១០, ១១

## ការចែករំលែកអាជីពជាគ្រូពេទ្យ និងការថែរក្សាសុខភាពចំពោះក្មេងស្រី

ពាមជីកង៖ នៅថ្ងៃចន្ទ ១០រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹង ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤ នៅវិទ្យាល័យ ហ៊ុន សែន ពាមជីកង បានរៀបចំកម្មវិធីសិក្ខាសាលាស្តីពី “ការចែករំលែកអាជីពជាគ្រូពេទ្យ និងការថែរក្សាសុខភាពចំពោះក្មេងស្រី” កម្មវិធីនេះរៀបចំឡើងដោយគ្រូប្រឹក្សាអាជីព និងធ្វើបទបង្ហាញដោយអ្នកគ្រូពេទ្យ ទូច ភិរម្យ ដែលធ្វើឡើងនៅសាលប្រជុំអគារធនធាននៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង នៅវេលាម៉ោង 8:00 am ដល់ 10:00 am ។

កម្មវិធីនេះធ្វើឡើងក្នុងគោលបំណង៖

- ចែករំលែកពីគន្លឹះក្នុងការត្រៀមខ្លួនជាគ្រូពេទ្យនៅថ្ងៃអនាគត
- ចែករំលែកពីការថែរក្សាសុខភាពបន្តពូជសម្រាប់ក្មេងស្រី។
















# បណ្ណាល័យសតវត្សទី២១ នៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង




បណ្ណាល័យគឺជាឃ្លាំងតម្កល់ នូវរាល់ឯកសារ និងជាកន្លែងផ្តល់នូវចំណេះដឹងដល់ សិស្ស និស្សិត កវីវិទូ បញ្ញវ័ន និងអ្នកវិទ្យាសាស្ត្រ ខិតខំស្រាវជ្រាវ ចងក្រង គូរ ថត ទុកជាស្នាដៃឬកេរ្តិ៍ សម្រាប់មនុស្សគ្រប់រូបស្រាវជ្រាវ ឬមុននឹងពួកគេបានក្លាយជាអ្នកឆ្នើមៗក្នុងការសម្រេចអ្វីមួយ។ យើងអាចនិយាយយ៉ាងងាយថា បណ្ណាល័យគឺជាឃ្លាំងប្រមូលផ្តុំ សៀវភៅ ទស្សនាវដ្តី ឯកសារ ទិន្នន័យកុំព្យូទ័រ ការរៀន ការអាន ការបញ្ចាំង តាមរយៈម៉ាស៊ីនផ្សេងៗ ដែលអ្នកជំនាន់មុនបានចងក្រងទុក។

ជាមួយគ្នានេះដែរ នៅវិទ្យាល័យ ហ៊ុន សែន ពាមជីកង មានបណ្ណាល័យមួយដែលបានបំពាក់ដោយបរិក្ខាទំនើបៗ ដូចជា កុំព្យូទ័រ ម៉ាស៊ីនព្រីន ថេបប្លែត ទូរទស្សន៍ សាឡុង តុ កៅអី ម៉ាស៊ីនចម្រោះទឹក ម៉ាស៊ីនត្រជាក់ វ៉ាយហ្វាយ និងមានសៀវភៅជាច្រើនសម្រាប់អោយលោកគ្រូ អ្នកគ្រូ សិស្សនុសិស្ស និងសាធារណៈជន ចូលអាន និងស្រាវជ្រាវមេរៀនផងដែរ។ បណ្ណាល័យសតវត្សរ៍ទី២១ នៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង បើកពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ និងអនុញ្ញាតឱ្យសិស្សចូលប្រើប្រាស់បណ្ណាល័យបានចាប់ពីពេលព្រឹករហូតដល់ពេលល្ងាច(ទោះបីម៉ោង១១រហូតដល់ម៉ោង១ ថ្ងៃត្រង់ក៏នៅបើកដំណើរការដែរ)។ ដូច្នេះសិស្សានុសិស្ស អាណាព្យាបាល និងសាធារណៈជន អាចមកអានសៀវភៅនៅបណ្ណាល័យបានចាប់ពីម៉ោង៧ព្រឹករហូតដល់ម៉ោង៥ល្ងាច ។











# ការរៀបចំធ្វើការីយ៉ូទីប





ពាមជីកង៖ នៅថ្ងៃអង្គារ ១១រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹង ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៤ អ្នកគ្រូ យឿន ពិសី គ្រូបង្រៀនមុខវិទ្យាជីវវិទ្យា បានដឹកនាំសិស្សថ្នាក់ទី11P1 ,11P2 ដែលកំពុងរៀនមេរៀនទី២៖ ក្រូម៉ូសូម បានលើកប្រធានបទមួយគឺ "ការរៀបចំធ្វើការីយ៉ូទីប" ដើម្បីឱ្យសិស្សានុសិស្សយល់កាន់តែច្បាស់ ព្រមទាំងផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត និងកាន់តែមានភាពទាក់ទាញ។

# វិទ្យាល័យ ហ៊ុន សែន ពាមជីកងជំនាន់ថ្មី

















# ការសម្តែង(Role play)ក្នុងអំណាន”អាពាហ៍ពិពាហ៍របស់ខ្មែរ”



ពាមជីកង៖ នៅថ្ងៃសុក្រ ១៤រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹង ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៤ លោកគ្រូ កង សំនាង បង្រៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ ថ្នាក់ទី១២ បានដឹកនាំសិស្សថ្នាក់ទី 12C2, 12P1 និងថ្នាក់ទី12P2 ក្រោមប្រធានបទ “ការសម្តែង(Role play)ក្នុងអំណាន«អាពាហ៍ពិពាហ៍របស់ខ្មែរ»”

កិច្ចពិធី(ថ្ងៃចូលរោង ថ្ងៃស៊ីស្លាកំណត់) ដែលសម្តែងមានដូចជា ពិធីជុំជាវខាន់ស្លា ពិធីបុកល័ក្ត ពិធីធ្វើធ្មេញ ពិធីហែជំនូន ពិធីជូនកំណត់ ពិធីកាត់សក់បង្កក់សិរី ពិធីសែនចងដៃ ពិធីសំពះផ្ទឹម បង្វិលពពិល ពិធីព្រះថោងតោងស្បៃ

វត្ថុបំណងនៃមេរៀន :

+ វិជ្ជាសម្បទា ៖ យល់ដឹងពីប្រពៃណី ទំនៀមទម្លាប់ និងដំណាក់កាលធំៗនៃអាពាហ៍ពិពាហ៍តាមរយៈការសិក្សាអត្ថបទ និងសម្តែង។

+ បំណិនសម្បទា ៖ រៀបរាប់បានយ៉ាងល្អអំពីពិធីសំខាន់ៗក្នុងអាពាហ៍ពិពាហ៍របស់ខ្មែរតាមរយៈការសម្តែង។

+ ចរិយាសម្បទា ៖បណ្តុះស្មារតីឱ្យស្រឡាញ់ ថែរក្សា និងគោរពតាមទំនៀមទម្លាប់ ប្រពៃណីដ៏ល្អផូរផង់របស់ខ្មែរយើង។













# ការញែក ADN ចេញពីផ្លែឈើទុំ (ផ្លែចេកណាំវ៉ា និង ផ្លែប៉េងប៉ោះ)





ពាមជីកង៖ នៅថ្ងៃអង្គារ ៤កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹង ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២៤ អ្នកគ្រូ យឿន ពិសី គ្រូបង្រៀនមុខវិទ្យាជីវវិទ្យា បានដឹកនាំសិស្សថ្នាក់ទី11P1 ,11P2 ដែលកំពុងរៀនមេរៀនទី២៖ ក្រូម៉ូសូម បានលើកប្រធានបទមួយគឺ "ការញែក ADN ចេញពីផ្លែឈើទុំ (ផ្លែចេកណាំវ៉ា និង ផ្លែប៉េងប៉ោះ)" ដើម្បីឱ្យសិស្សានុសិស្សយល់កាន់តែច្បាស់ ព្រមទាំងផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត និងកាន់តែមានភាពទាក់ទាញ។














ការអភិវឌ្ឍបំណិនជីវិតសំខាន់សម្រាប់ការរៀបចំខ្លួនកុមារឱ្យសម្រេចបានសក្តានុពលរបស់ពួកគេ និងអាចឱ្យគេប្រកាន់យកវិធានការច្បាស់លាស់ ដែលអាចឈានទៅរកគោលដៅផ្ទាល់ខ្លួន និងសហគមន៍។ បំណិនជីវិតកុមារ ជាចំណេះដឹង ឥរិយាបទ និងសមត្ថភាពដែលឱ្យកុមារដោះស្រាយដោយមានប្រសិទ្ធិភាព ជម្នះឧបសគ្គ និងការប្រឈមទាំងឡាយក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ មិនថានៅផ្ទះ សាលារៀន ការងារ ឬសហគមន៍នោះឡើយ។ ជាមួយគ្នានេះដែរ វិទ្យាល័យ ហ៊ុន សែន ពាមជីកង បានបន្ថែមមុខវិជ្ជាះបំណិនជីវិត ដល់សិស្សានុសិស្ស ដើម្បីឱ្យគាត់អាចយកទៅប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ។

ដូចនេះ នៅថ្ងៃសុក្រ ទី១២ ខែកក្កដា ឆ្នាំ២០២៤ លោកគ្រូ អ៊ី លឹមហៅ បានដឹកនាំសិស្សានុសិស្សថ្នាក់ទី៨ “P1” មើលថែដំណាំដែលបានដាំនៅក្នុងសួនបំណិនជីវិត ដោយបានដកស្មៅនៅតាមរងស្ពៃក្តោបដើម្បីស្ពៃលូតលាស់កាន់តែល្អ។






# សកម្មភាពប្រឡងឆមាសលើកទី២ ថ្នាក់ទី១២



ពាមជីកង៖ នៅថ្ងៃចន្ទ ១០កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹង ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤ សិស្សានុសិស្សថ្នាក់ទី១២ បានប្រឡងឆមាសទី២ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ នៅក្នុងវិទ្យាល័យ ហ៊ុន សែន ពាមជីកង ដោយភាពតឹងរឹងបំផុត។ នៅតាមបន្ទប់ប្រឡងមានគណៈកម្មការអនុរក្សចំនួនពីរនាក់ គណៈកម្មការត្រួតពិនិត្យអគារមួយនាក់ ដើម្បីត្រួតពិនិត្យការប្រឡងឆមាសទី២។ សិស្សានុសិស្សបានខិតខំយ៉ាងយកចិត្តទុកដាក់ក្នុងការប្រឡងលើវិញ្ញាសានីមួយៗ និងពោរពេញដោយក្តីសង្ឃឹម និងទន្ទឹងរង់ចាំមើលលទ្ធផលប្រឡងរបស់ខ្លួន។ ការប្រឡងប្រព្រឹត្តទៅយ៉ាងល្អ បេក្ខជនគ្រប់បន្ទប់បានគោរពនូវបញ្ញាត្តិក្នុងពេលប្រឡងបានយ៉ាងល្អខ្ជាប់ខ្ជួន។









# ពិធីសំណេះសំណាលជាមួយសិស្សថ្នាក់ទី១២ នៃវិទ្យាល័យហ៊ុន សែនពាមជីកង

ពាមជីកង៖ នាព្រឹកថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានអញ្ជើញជួបសំណេះសំណាលជាមួយសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម និងមានការចូលរួមពី អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួង នាយក នាយិកា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់សរុបប្រមាណ ១៨១នាក់។

ក្នុងឱកាសនេះ ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី បានសម្ដែងនូវការសួរសុខទុក្ខ និងអនុសាសន៍ដល់ក្មួយៗ សិស្សានុសិស្សថ្នាក់ទី១២ ដែលត្រៀមនឹងប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនាពេលខាងមុខនេះដូចតទៅ៖

- ស្នើសុំឱ្យមានការរៀបចំថ្នាក់បំប៉នសម្រាប់សិស្សឱ្យរៀនបន្ថែមលើមុខវិជ្ជាសំខាន់ៗ ជាពិសេសផ្ដោតលើមេរៀនសង្ខេបតាមមុខវិជ្ជានីមួយៗ និងសិក្សាស្វែងយល់ពីវិញ្ញាសាដែលធ្លាប់ចេញប្រឡងពីឆ្នាំមុនៗជាដើម។
- ផ្ដោតលើមុខវិជ្ជា ដូចជាគណិតវិទ្យា និងភាសាខ្មែរ សម្រាប់គណិតវិទ្យា ព្យាយាមធ្វើលំហាត់ និងសរសេររូបមន្តឱ្យបានច្រើនរបៀបធ្វើលំហាត់ខុសៗគ្នា និងចងចាំរូបមន្តឱ្យកាន់តែច្បាស់ថែមទៀត សម្រាប់មុខវិជ្ជាភាសាខ្មែរ រៀនពីរបៀបសរសេរតែងសេចក្ដី របៀបប្រើប្រាស់ពាក្យភ្ជាប់ និងចេះលើកឧទាហរណ៍មកបញ្ជាក់ឱ្យបានសមស្របទៅតាមប្រធានបទនីមួយៗ។
- ចេះគ្រប់គ្រងពេលវេលាឱ្យបានល្អ តាំងអារម្មណ៍ឱ្យបានស្ងប់ ជាពិសេសថែរក្សាសុខភាពឱ្យបានល្អ ដូចជាការគេង និងបរិភោគអាហារឱ្យបានគ្រប់គ្រាន់ ដើម្បីកុំឱ្យមានបញ្ហាអ្វីកើតឡើងមុន ឬក្នុងពេលប្រឡង។
- ចេះសង្ខេបមេរៀនដោយខ្លួនឯង និងរំលឹកមេរៀនពីដើមឆ្នាំមកវិញ តាមឯកសារមេរៀនសង្ខេប ដើម្បីកុំមានការភ្លេចភ្លាំងផ្សេងៗ។

ជាកិច្ចបញ្ចប់ ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី បានផ្ដល់ជូននូវសៀវភៅមេរៀនសង្ខេប ដើម្បីជាឯកសារជំនួយដល់ការរៀនសូត្រ និងផ្ដល់នូវគន្លឹះសិក្សាមួយចំនួនដល់សិស្សានុសិស្ស ដើម្បីត្រៀមខ្លួនរួចរាល់សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងសូមថ្លែងអំណរគុណដល់អ្នកពាក់ព័ន្ធទាំងអស់ដែលបានខិតខំប្រឹងប្រែងជួយគាំទ្រលើវិស័យអប់រំនាពេលកន្លងមក ជាពិសេសសម្រាប់ស្រុកកងមាសនេះ និងសូមជូនពរដល់សិស្សានុសិស្សទាំងអស់ឱ្យទទួលបានលទ្ធផលល្អសម្រាប់ការប្រឡងនាពេលខាងមុខនេះ៕








# សកម្មភាពប្រឡងឆមាសលើកទី២ ថ្នាក់ទី៩



ពាមជីកង៖ នៅថ្ងៃចន្ទ ២រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹង ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤ សិស្សានុសិស្សថ្នាក់ទី៩ បានប្រឡងឆមាសលើកទី២ សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤ នៅតាមអគារសិក្សារបស់វិទ្យាល័យ ហ៊ុន សែន ពាមជីកង ដោយការប្រឡងមានភាពតឹងរឹងបំផុត។ នៅតាមបន្ទប់ប្រឡងនីមួយៗ មានគណៈកម្មការអនុរក្សចំនួនពីរនាក់ និងនៅតាមអគារប្រឡងនីមួយៗមានគណៈកម្មការត្រួតពិនិត្យអគារចំនួនមួយនាក់។ នៅក្នុងការប្រឡងឆមាសលើកទី២ របស់សិស្សថ្នាក់ទី៩ បេក្ខជនប្រឡងបានខិតខំយ៉ាងយកចិត្តទុកដាក់ក្នុងការធ្វើវិញ្ញាសានីមួយៗ និងពោរពេញដោយក្តីសង្ឃឹម និងទន្ទឹងរង់ចាំមើលលទ្ធផលប្រឡងរបស់ខ្លួន។ ការប្រឡងប្រព្រឹត្តទៅយ៉ាងល្អ សិស្សានុសិស្សគ្រប់កម្រិតថ្នាក់បានគោរពនូវបញ្ញាត្តិក្នុងពេលប្រឡងបានយ៉ាងខ្ជាប់ខ្ជួន។









# សកម្មភាពប្រឡងប្រចាំខែកក្កដា ថ្នាក់ទី៧, ៨, ១០, ១១



ពាមជីកង៖ នៅថ្ងៃព្រហស្បតិ៍ ៥រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹង ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ វិទ្យាល័យ ហ៊ុន សែន ពាមជីកង បានរៀបចំការប្រឡងប្រចាំខែកក្កដា ដល់សិស្សានុសិស្សថ្នាក់ទី៧, ៨, ១០ និងទី១១ សម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤ នៅតាមអគារសិក្សារៀងៗខ្លួនដោយភាពតឹងរឹងបំផុត ហើយនៅតាមបន្ទប់ប្រឡងមានគណៈកម្មការអនុរក្សចំនួនពីរនាក់ និងនៅតាមអគារប្រឡងនីមួយៗមានគណៈកម្មការត្រួតពិនិត្យអគារចំនួនមួយនាក់។ សិស្សានុសិស្សបានខិតខំយ៉ាងយកចិត្តទុកដាក់ក្នុងការប្រឡងលើវិញ្ញាសានីមួយៗ និងពោរពេញដោយក្តីសង្ឃឹម និងទន្ទឹងរង់ចាំមើលលទ្ធផលប្រឡងរបស់ខ្លួន។ ការប្រឡងប្រព្រឹត្តទៅយ៉ាងល្អ សិស្សានុសិស្សគ្រប់កម្រិតថ្នាក់បានគោរពនូវបញ្ញាត្តិក្នុងពេលប្រឡងបានយ៉ាងខ្ជាប់ខ្ជួន។







